**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រដ្ឋបាលព្រៃឈើ
នាយកដ្ឋានព្រៃឈើ និងសហគមន៍ព្រៃឈើ

ភ្នំពេញ ថ្ងៃទី ខែឧសភា ឆ្នាំ២០១៤

ក្រុមការងារ វាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ (MRV)

**សូមគោរពជូន**

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ**

**កម្មវត្ថុ:** របាយការណ៍ស្តីពីលទ្ធផលអង្គប្រជុំបច្ចេកទេសវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់(MRV) លើកទី៩។

**ជូនភ្ជាប់:** -រូបថតសកម្មភាពនៃកិច្ចប្រជុំ..........................................................................ចំនួន១ច្បាប់

-បញ្ជីវត្តមាន................................................................................................ចំនួន១ច្បាប់

-សេចក្តីព្រាងផែនការសកម្មភាព......................................................................ចំនួន១ច្បាប់

ន័យដូចមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើ យើងខ្ញុំសូមអនុញ្ញាតជម្រាបជូនឯកឧត្តមប្រតិភូមេត្តាជ្រាបថា កាលពីថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១៤ ក្រុមការងារបច្ចេកទេស វាស់វែង រាយការណ៍ និង ផ្ទៀងផ្ទាត់ (MRV) បានរៀបចំកិច្ចប្រជុំលើកទី៩ នៅសណ្ឋាគារ អ៊ីមផារៀលហ្គាដិនវីឡា ដែលទទួលបានលទ្ធផលដូចខាងក្រោម៖

## ១.សមាសភាពចូលរួម

កិច្ចប្រជុំនេះមានសមាជិកចូលរួមចំនួន ០៩ នាក់ (ដូចបញ្ជីវត្តមាននៃឯកសារជូនភ្ជាប់) មកពី៖

-រដ្ឋាភិបាលៈ រដ្ឋបាលព្រៃឈើ ក្រសួងបរិស្ថាន សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

-ក្រុមប្រឹក្សាយោបល់ៈ អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ (FAO) ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ នៃប្រទេសជប៉ុន(JICA) សមាគមន៍ជនជាតិដើមភាគតិចកម្ពុជា (CIYA) ។

## ២.គោលបំណងនៃអង្គប្រជុំ

គោលបំណងនៃអង្គប្រជុំស្តីពីការពិភាក្សាបញ្ចប់លើពង្រាងផែនការសកម្មភាពរបស់ក្រុមការងារ MRV/REL ។

## ៣.ដំណើរការកិច្ចប្រជុំ

អង្គប្រជុំបានបន្តធ្វើការពិនិត្យ និងកែសម្រួលឡើងវិញ លើខ្លឹមសារក្នុងសេចក្តីព្រាងផែនការសកម្មភាព MRV/REL ចាប់ពី Output ៤.២ ព្រមទាំងកំណត់អ្នកទទួលខុសត្រូវលើគ្រប់សកម្មភាព និងធ្វើការកំណត់លើតារាងពេលវេលាសម្រាប់អនុវត្តសកម្មភាពនីមួយៗ។

## ៤.លទ្ធផលនៃកិច្ចប្រជុំ

អង្គប្រជុំបានសម្រេចនូវសេចក្តីព្រាងផែនការសកម្មភាពរបស់ក្រុមការងារ MRV/REL និងបានកំណត់ពេលវេលាសម្រាប់អនុវត្តសកម្មភាពនីមួយៗបានចប់សព្វគ្រប់ជាស្ថាពរ (ដូចឯកសារជូនភ្ជាប់)។

## ៥.ទិសដៅអនុវត្តបន្ត

- ក្រុមការងារនឹងដាក់សេចក្តីព្រាងផែនការសកម្មភាពនេះជូនក្រុមការងាររេដ+កម្ពុជាធ្វើការពិនិត្យ នឹងផ្តល់អនុសាសន៍កែសម្រួល។
- ក្រុមការងារនឹងរៀបចំប្រជុំលើកទី១០ នៅសប្តាហ៍ទីមួយខែមិថុនាស្តីពីការកែសម្រួលតាមអនុសាសន៍ក្រុមការងាររេដ+កម្ពុជា និងការអនុវត្តផែនការសកម្មភាព។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមប្រតិភូមេត្តាពិនិត្យសម្រេចដោយអនុគ្រោះតាមការគួរ ។

# រូបថតសកម្មភាពនៃកច្ចប្រជុំ MRV លើកទី៩



